ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ដែលពាក់ព័ន្ធនឹងដីសម្បទានព្រៃឈើ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ លើផ្ទៃដីសរុប ១ ៥១៩ ហិកតា ដើម្បីធ្វើប្រទានកម្មដីជូនប្រជាពលរដ្ឋកាន់កាប់

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណ:រដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណ:របស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណ:

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សា គោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដី សេដ្ឋកិច្ច
- បានឃើញសារាចរ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកែលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញដីកាលេខ ០០៨/០៦ អគខ.ដព ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៦ របស់សាលាខេត្ត កំពង់ចាម ស្តីពីការដកហូតដីព្រៃឈើ ដែលមានការទន្ទ្រានចូលកាន់កាប់ខុសច្បាប់
- បានឃើញកំណត់ហេតុចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ របស់គណៈកម្មការត្រួតពិនិត្យនិងកំណត់អត្តសញ្ញាណដីនៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- តាមសំណើលេខ ១៧១៦លខកច និងលេខ ១៧១៨លខកច ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ ៖**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០០២ និងពីដីសម្បទានព្រៃឈើដែលបានផ្តល់ដល់ក្រុមហ៊ុនព្រៃសម្បទានជីម៉ាស់វីសូសលីមីធីត ហើយធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីសរុបចំនួន **១.៥១៩**ហ.ត (មួយពាន់ប្រាំរយដប់ប្រាំបួនហិកតា) ដែលមានទីតាំងស្ថិតនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងនោះមាន៖

- នៅភូមិប្រទង ឃុំអូរម្លូ លើផ្ទៃដីចំនួន **៦០៨** ហ.ត (ប្រាំមួយរយប្រាំបីហិកតា) និង
- នៅភូមិគីឡូម៉ែត្រលេខ ១០ ឃុំអារក្សត្នោតលើផ្ទៃដីចំនួន **៩១១**ហ.ត (ប្រាំបួនរយដប់មួយហិកតា)

ដែលផ្ទៃដីទាំងពីរខាងលើនេះត្រូវបានកំណត់តាមប្រពន្ធ័កូអរដោណេ Project UTM Zone 48N Datum wgs 1984 ដូចក្នុងផែនទី និងចំណុចគោលនៃក្បាលដីនីមួយៗមានភ្ជាប់ក្នុងឧបសម្ព័ន្ធ I និងII នៃអនុក្រឹត្យនេះ និងដែលមាននិយាមកាដូចខាងក្រោម ៖

**១-សម្រាប់ផ្ទៃដីចំនួន ៦០៨ ហ.ត នៅភូមិប្រទង ឃុំអូរម្លូ ៖**

| ចំណុច | X | Y |
|---|---|---|
| 1 | 564081 | 1376277 |

| ចំណុច | X | Y |
|---|---|---|
| 6 | 564083 | 1372687 |

| | | | | | |
|---|---|---|---|---|---|
| 2 | 565036 | 1375891 | 7 | 563691 | 1373170 |
| 3 | 565485 | 1375069 | 8 | 563634 | 1374095 |
| 4 | 565893 | 1374320 | 9 | 564137 | 1375768 |
| 5 | 565890 | 1372709 | | | |

**២-សម្រាប់ផ្ទៃដីចំនួន ៩១១ហ.ត នៅភូមិគីឡូម៉ែត្រលេខ ១០ ឃុំអារក្សត្នោត ៖**

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 566578 | 1372320 | 8 | 567181 | 1374778 |
| 2 | 566578 | 1372005 | 9 | 566479 | 1374919 |
| 3 | 566937 | 1371982 | 10 | 566056 | 1375194 |
| 4 | 567364 | 1369210 | 11 | 565730 | 1375615 |
| 5 | 568578 | 1369320 | 12 | 565485 | 1375069 |
| 6 | 568991 | 1370320 | 13 | 565893 | 1374320 |
| 7 | 568286 | 1371534 | 14 | 565890 | 1372709 |

**មាត្រា ២ ៖**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រងនិងធ្វើប្រទានកម្មផ្តល់ជូនប្រជាពលរដ្ឋចំនួន **២៣០** (ពីររយសាមសិប)គ្រួសារ ដែលបានកាន់កាប់និងប្រើប្រាស់ដីនោះជាក់ស្តែង ដើម្បីមានសិទ្ធិកាន់កាប់ស្របច្បាប់ទៅតាមទំហំដីជាក់ស្តែង ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋនិងរដ្ឋបាលសុរិយោដីខេត្តកំពង់ចាមបានធ្វើការអង្កេតនិងវាស់វែងស្របតាមនីតិវិធីនៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋនិងអនុក្រឹត្យទាក់ទងនឹងការងារចុះបញ្ជីដីធ្លី ក្នុងនោះចំនួន **១២០(មួយរយម្ភៃ)** **គ្រួសារ**នៅក្នុង**ភូមិប្រទង ឃុំអូរម្លូ** ស្រុកស្ទឹងត្រង់ និងចំនួន **១១០(មួយរយដប់)គ្រួសារ នៅភូមិគីឡូម៉ែត្រលេខ១០ ឃុំអារក្សត្នោត** ស្រុកស្ទឹងត្រង់។

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកដីជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ត្រូវគិតបញ្ចូលនិងកាត់ចេញនូវចំណែកដីមួយចំនួនដែលនឹងត្រូវរក្សាទុក សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនិងសង្គមក្នុងមូលដ្ឋានផ្ទាល់ ។

**មាត្រា ៣ ៖**

ក្នុងពេលរង់ចាំដំណើរការចុះបញ្ជីដីធ្លីតាមនីតិវិធីបានបញ្ចប់ជាស្ថាពរ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាមត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិបឋមលើដីនោះ ដូចមានគម្រូក្នុងឧបសម្ព័ន្ធ III នៃអនុក្រឹត្យនេះ ដល់ប្រជាពលរដ្ឋដែលទទួលបានដី ក្នុងនោះត្រូវធ្វើប្រទានកម្មជាកម្មសិទ្ធិឯកជនលើចំណែកដីមិនលើសពី ០៥ (ប្រាំ) ហិកតា លើកលែងតែដីដែលបានដាំដំណាំរួច ដូចជាកៅស៊ូជាដើម អាចផ្តល់ជាកម្មសិទ្ធិឯកជន ក្នុងទំហំមិនលើសពី ២០០ (ពីររយហិកតា) ។

**មាត្រា ៤ ៖**

ចំណែកដីនៅសល់ពីការធ្វើប្រទានកម្មដូចចែងក្នុងមាត្រា ៣ ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម និងអាចផ្តល់ប្រទានកម្មនូវសិទ្ធិសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដោយត្រូវផ្តល់លិខិតបញ្ជាក់ការប្រើប្រាស់ដីរដ្ឋក្នុងរូបភាពសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដូចមានគម្រូក្នុង

ឧបសម្ព័ន្ធទី IV នៃអនុក្រឹត្យនេះ ក្នុងពេលរង់ចាំការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចខ្នាតតូចជាផ្លូវការ ទៅតាមគម្រូកិច្ចសន្យាដូចមានក្នុងឧបសម្ព័ន្ធ V នៃអនុក្រឹត្យនេះ។

**មាត្រា ៥ ៖**

កម្រៃសេវាសុរិយោដី និងកាតព្វកិច្ចពន្ធផ្សេងៗដែលមានជាប់ពាក់ព័ន្ធជាបន្ទុករបស់រដ្ឋ។ដោយឡែក ករណីសម្បទានដីសេដ្ឋកិច្ចខ្នាតតូច គឺត្រូវអនុវត្តតាមកិច្ចសន្យាដែលបានព្រមព្រៀងរវាងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត និងសម្បទានិកដីសេដ្ឋកិច្ចខ្នាតតូចនៃក្បាលដីនោះ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាមត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ